# សេចក្ដីសង្ខេបស្ដីពីអត្ថប្រយោជន៍ធ្មេញរបស់អ្នក



សូមអរគុណសម្រាប់ការក្លាយជាផ្នែកមួយនៃកម្មវិធីធ្មេញ Medi-Cal ។ ការមើលថែសុខភាពមាត់ធ្មេញរបស់អ្នក គឺជាផ្នែកមួយដ៏សំខាន់នៃសុខភាពទូទៅរបស់អ្នក។ វិធីមួយក្នុងចំណោមវិធីដ៏ល្អបំផុតក្នុងការប្រើអត្ថប្រយោជន៍ធ្មេញរបស់អ្នក គឺត្រូវជ្រើសរើសផ្ទះថែទាំធ្មេញមួយ។ ផ្ទះថែទាំធ្មេញ គឺជាពេទ្យធ្មេញធម្មតាដែលអាចជួយរក្សាស្នាមញញឹមរបស់អ្នកឲ្យមានសុខភាពល្អ ហើយផ្ដល់ការថែទាំនៅពេលអ្នកត្រូវការវា។

## ត្រូវការស្វែងរកពេទ្យធ្មេញទេ?

ដើម្បីស្វែងរកពេទ្យធ្មេញដែលនៅក្បែរអ្នក សូមស្កេនកូដ QR នេះ ឬចូលមើល bit.ly/ca-findadentist ។

## អត្ថប្រយោជន៍ធ្មេញរបស់អ្នក

មគ្គុទ្ទេសក៍នេះបង្ហាញពីអត្ថប្រយោជន៍ធ្មេញ សេវាកម្ម និងជំនួយគាំទ្រខ្លះៗដែលមានផ្ដល់ជូនតាមរយៈកម្មវិធីធ្មេញ Medi-Cal ។

## សេវាកម្មបង្ការ

ទទួលបានការថែទាំធ្មេញបង្ការ ដោយឥតគិតថ្លៃ រាប់បញ្ចូលទាំង៖

- ការពិនិត្យធ្មេញ
- ការសម្អាតធ្មេញ
- ការថតកាំរស្មីអ៊ិក
- ការព្យាបាលដោយប្រើភ្លុយអរ
- ថ្នាំបិទភ្ជិត

## សេវាកម្មបន្ថែមសម្រាប់សមាជិកដែលមានអាយុក្រោម 21 ឆ្នាំ

សមាជិកដែលមានអាយុក្រោម 21 ឆ្នាំ អាចទទួលបានសេវាកម្មធ្មេញបន្ថែមតាមរយៈអត្ថប្រយោជន៍ការពិនិត្យរោគវិនិច្ឆ័យ និងការព្យាបាលសម្រាប់កុមារ និងជាប្រចាំ (EPSDT) ។

## មើលអត្ថប្រយោជន៍ទាំងអស់របស់អ្នក

ស្កេនកូដ QR នេះ ឬចូលមើល bit.ly/ca-benefits ដើម្បីស្វែងយល់បន្ថែមអំពីអត្ថប្រយោជន៍ធ្មេញដែលមានការរ៉ាប់រងរបស់អ្នក។

## ការថែទាំធ្មេញករណីបន្ទាន់ 24/7

ត្រូវការជំនួយក្នុងករណីបន្ទាន់នៃធ្មេញឬ? និយាយជាមួយអ្នកផ្ដល់សេវាធ្មេញ នៅពេលណាក៏បាន មិនថាពេលថ្ងៃ ឬយប់ឡើយ។ ចូលអនឡាញ ឬទូរសព្ទមកយើង ដូចខាងក្រោម៖

### សេវាកម្មពិនិត្យធ្មេញពីចម្ងាយ

ទូរសព្ទ៖ (866) 302-0905 ឬស្កេនកូដ QR ឬចូលមើល bit.ly/ca-teledentist ។

## សេវាកម្មជំនួយគាំទ្រដែលអាចរកបាន

- រៀបចំការដឹកជញ្ជូនទៅកាន់ការណាត់ជួបពិនិត្យធ្មេញ និងត្រឡប់មកវិញ។
- ទទួលបានសេវាកម្មអ្នកបកប្រែភាសាផ្ទាល់មាត់ រាប់ទាំង ជំនួយខាងភាសាសញ្ញាផងដែរ។
- ទទួលបានឯកសារជាភាសាដែលអ្នកចង់បាន ឬជាទម្រង់ដែលអាចប្រើបានដូចជា អក្សរពុម្ពធំ ឬជាសំឡេង។



## មានសំណួរទេ?

សេវាកម្មសមាជិកអាចឆ្លើយសំណួរអំពីអត្ថប្រយោជន៍ធ្មេញរបស់អ្នក ហើយជួយអ្នកឲ្យចូលប្រើសេវាកម្មនានាដែលមានរ៉ាប់រង។

**ខោនធី Los Angeles**
855-388-6257

**ខោនធី Sacramento**
833-479-1984

**TTY**
800-466-7566 ឬ 711

DentaQuest
Benefits provided by California Dental Network

*អត្ថប្រយោជន៍ធ្មេញត្រូវបានផ្ដល់ជូនដោយ California Dental Network ។ California Dental Network ធ្វើកិច្ចការធុរកិច្ចជា DentaQuest ។ ក្នុងឯកសារនេះទាំងមូល California Dental Network គឺសំដៅទៅ*

DQ4210 (7.26) CAM